# នួន ជា សម្រេចឆ្លើយតបនឹងសំនួរខណៈពេលដែលសាក្សី ស្ទីវ ហេដឌ័រ បន្តផ្តល់សក្ខីកម្ម

**ដោយ សាយមិន ក្រូស័រ**

**ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣**

*ប្រែសម្រួលដោយ គឹមស្រួយ សុខវិសាល*

នៅថ្ងៃពុធ ទី១៧ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តស្តាប់សក្ខីកម្ម លោក ស្ទីវ ហេដឌ័រ តាមរយៈការសួរដេញដោលដោយមេធាវីការពារក្តី ខៀវ សំផន ។

មុនពេលអង្គជំនុំជម្រះប្រគល់វេទិកាជូនមេធាវីការពារក្តី ខៀវ សំផន សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនចង់បញ្ជាក់អំពីទំនាក់ទំនងរវាងមនោគមវិជ្ជាកុម្មុយនីស្ត និងជនជាប់ចោទ ។ សាក្សីចង់បញ្ជាក់ពីប្រភព ឯកសារនៃកំណត់សំគាល់ជើងទំព័រដែលភាគីមានការខ្វែងគំនិតគ្នាកាលពីថ្ងៃមុន ។ ប្រធានអង្គជំនុំជម្រះសាលដំបូង និល ណុន បានបដិសេធសំណើរទាំងពីរនេះ ហើយក្រើនរំឭកឲ្យសាក្សីឆ្លើយនឹងសំនួររបស់មេធាវីការពារក្តី ។ លោកប្រធាន និល ណុន ក៏បានរំឭកឲ្យសាក្សីឆ្លើយឲ្យចំនឹងសំនួររបស់មេធាវីការពារក្តី ។

មុនពេលមេធាវីការពារក្តី ខៀវ សំផន សួរដេញដោលសាក្សី សហព្រះរាជអាជ្ញា ឃីត វ៉េយ៍ន័រ បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះថា ឯកសារមួយចំនួនរបស់មេធាវីការពារក្តី ខៀវ សំផន ពុំមាននៅក្នុងខបសម្ព័ន្ធថ្មីទេ ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារទាំងនេះត្រូវតែចុះឈ្មោះនៅក្នុងបញ្ជីមុននឹងយកមកប្រើប្រាស់នៅក្នុងសវនាការ ។

មេធាវីការពារក្តី ខៀវ សំផន អង់តា ហ្គីសសេ បានឆ្លើយតបនឹងសហព្រះរាជអាជ្ញាវិញថា ការលើកឡើងបែបនេះពុំមានហេតុផលច្បាស់លាស់ ប៉ុន្តែបានបញ្ជាក់ថា មេធាវីការពារក្តី ខៀវ សំផន នឹងបង្ហាញឯកសាររបស់ខ្លួនជូនអង្គជំនុំជម្រះ ។

## មេធាវីការពារក្ដី ខៀវ សំផន សួរដេញដោលសាក្សី

មេធាវី ហ៊្គីសសេ បានចាប់ផ្ដើមដោយបញ្ជាក់ថា មេធាវីការពារចង់បានការឆ្លើយតបដ៏ជាក់លាក់ពីសំណាក់សាក្សីទាក់ទងនឹងសំនួរទាំងអស់របស់ខ្លួន ។ មេធាវី ហ៊្គីសេ សួរដេញដោលអំពីសកម្មភាពរបសសាក្សីនៅចន្លោះខែឧសភា ឆ្នាំ១៩៧៣ ដល់ខែមេសា ឆ្នាំ១៩៧៥ ។ សាក្សីបាន បញ្ជាក់ថា នៅពេលដែលខ្លួនមកដល់ទីក្រុងភ្នំពេញ សហរដ្ឋអាមេរិចបានចាប់ផ្ដើមទម្លាក់គ្រាប់បែកក្នុងកម្ពុជារហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ។ ពេលនោះ សាក្សីមិនបានរស់នៅក្នុងតំបន់ដែលទទួលរងគ្រោះដោយការទម្លាក់គ្រាប់បែកនោះទេ ។ សាក្សីរស់នៅប៉ែកនិរតីជាយទីក្រុងភ្នំពេញ ប៉ុន្តែពេលនោះសាក្សីបានដឹង និងឮសម្លេងគ្រាប់បែកផ្ទុះ ។ សាក្សីមិនបានទៅពិនិត្យមើលកន្លែងរងគ្រោះដោយការទម្លាក់គ្រាប់បែក និងតំបន់ដែលកាន់កាប់ដោយខ្មែរក្រហមនោះទេ ។

មេធាវី ហ៊្គីសសេ ជម្រាបជូនអង្គជំនុំជម្រះពីឯកសារចំនួនពីច្បាប់ដែលសហព្រះរាជអាជ្ញាបានលើកយកមកពិភាក្សា ហើយឯកសារទាំងពីរនេះមានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធទីមួយរបស់ការិយាល័យសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា នេះគឺជាបញ្ជីខុសហើយឯកសារនេះគួរតែត្រូវបានដាក់នៅក្នុងបញ្ជីថ្មី ។ មេធាវីការពារក្ដីបានបដិសេធចំពោះការលើកឡើងនេះដោយអះអាងថា ឯកសារនេះមានលេខ E3 ។

មេធាវី ហ៊្គីសសេ បានរំឭកសាក្សីថា កាលពីថ្ងៃទី១១ ខែកក្កដា សាក្សីបាននិយាយថាខ្លួនបានទទួលព័ត៌មានពីបុគ្គលិកយោធាជប៉ុនដែលធ្វើការនៅស្ថានទូត ។ មេធាវី ហ៊្គីសសេ បានស្នើរឲ្យសាក្សីបញ្ជាក់ថាតើរបប លន់ នល់ មានកងទ័ពជើងអាកាសដែរឬទេ ។ សហព្រះរាជអាជ្ញា វ៉ើយ័ន័រ បានជំទាស់ដោយលើកឡើងថា សាក្សីបានឆ្លើយនឹងសំនួរបែបនេះរួចហើយ ។

បន្ទាប់ពីបានបញ្ជាក់ថា “ខ្លួនទទួលយក” ការជំទាស់នេះ មេធាវី ហ៊្គីសសេ បានចោទសួរថាតើសាក្សីដឹងថារបប លន់ នល់ មានកងទ័ពជើងអាកាសដោយរបៀបណា ។ សាក្សីបានឆ្លើយតបថាខ្លួនបានដឹងព័ត៌មាននេះពីកងទ័ពជើងអាកាស លន់ នល់ ផ្ទាល់ ស្ថានទូតអាមេរិក និងបុគ្គលិកយោធាជប៉ុនដែលធ្វើការនៅស្ថានទូត ។ ទាក់ទងនឹងសក្ខីកម្មរបស់លោក ស៊ីដនី ស្កេនប័ច ដែលបានរៀបរាប់អំពីការ

ទម្លាក់គ្រាប់បែកនៅថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៥ សាក្សីបានបញ្ជាក់ថាពិតជាមានការទម្លាក់គ្រាប់បែកមែន ជាពិសេសដោយយន្តហោះ T28 ។

នៅខណៈពេលដែលភាគីធ្វើការជំទាស់ទៅវិញទៅមក សហព្រះរាជអាជ្ញា វេរ៉យ័ន័រ បានអះអាងថា "ការមិនយកចិត្តទុកដាក់ មិនត្រឹមតែធ្វើឲ្យប៉ះពាល់ដល់មេធាវីការពារក្តីនោះទេ ប៉ុន្តែ នាំឲ្យមានការប៉ះពាល់ដល់ប្រព័ន្ធតុលាការទាំងមូល" ។ ដូច្នេះ មេធាវីការពារក្តីគួរបញ្ជាក់ជូនអង្គជំនុំជម្រះអំពីលេខទំព័រ និងលេខ ERN ។ សហព្រះរាជអាជ្ញាបានចោទប្រកាន់មេធាវីការពារក្តីថា "ពុំមានវិជ្ជាជីវៈជាមេធាវី" ។

មេធាវី ហ្គីសសេ បានឆ្លើយតបថា "ខ្ញុំយល់ឃើញថា សហព្រះរាជអជ្ញាមានចេតនាជំទាស់នឹងសំនួរទាំងអស់របស់ខ្ញុំ ។ បើសិនជាតម្រូវឲ្យយើងបន្តបែបនេះទៀតយើងនឹងធ្វើ" ។ មេធាវី ហ្គីសសេ ក៏បានលើកឡើងថាខ្លួនបានបង្ហាញឯកសារយោងរួចហើយ ។

លោកប្រធានអង្គជំនុំជម្រះសាលាដំបូងបានបង្អាក់សហព្រះរាជអជ្ញា ហើយលើកឡើងថាសហព្រះរាជអាជ្ញាបានធ្វើការជំទាស់ជាច្រើនដងរួចមកហើយ ដូច្នេះត្រូវទុកពេលវេលាឲ្យមេធាវីការពារក្តីដើម្បីមានឱកាសសួរដេញដោលសាក្សី ។

បន្ទាប់មកទៀត មេធាវី ហ្គីសសេ បានលើកឡើងអំពីរបាយការណ៍សម្ងាត់ដែលសាក្សី បានជម្រាបជូនអង្គជំនុំជម្រះអំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្មែរក្រហមកាលពីសវនាការមុន ។ ពេលនោះ សាក្សីបានលើកឡើងថា មានភស្តុតាងមួយចំនួនដែលបញ្ជាក់ថា សាឡុត ស (ប៉ុល ពត) ស្ថិតនៅក្នុងលេខរៀងខាងលើបំផុតនៃតារាង ។ សាក្សីនៅចងចាំថាខ្លួនពិតជាបានលើកឡើងបែបនេះ ហើយឈ្មោះ សាឡុត ស ពិតជាស្ថិតនៅលើគេក្នុងតារាងនោះមែន ។ សាក្សីបានបន្ថែមថា ពេលនោះ សាឡុត ស ពុំបានប្រើឈ្មោះហៅក្រៅផ្សេងទៀតឡើយ ហើយសាក្សីក៏មិនបានដឹងអំពីឈ្មោះ ប៉ុល ពត នោះទេ ។

សាក្សីបានបន្តថា ពេលនោះមានការពិភាក្សាគ្នាក្នុងចំណោមភ្នាក់ងារសម្ងាត់ជាច្រើនថាតើ ប៉ុល ពត ឬអ្នកផ្សេងជាថ្នាក់ដឹកនាំកំពូលរបស់ចលនាខ្មែរក្រហម ហើយភាពមិនច្បាស់លាស់នេះធ្វើឲ្យមានការសន្និដ្ឋានថា មាន "ថ្នាក់ដឹកនាំកំពូលបី" ដែលម្នាក់ក្នុងចំណោមនោះ គឺ ខៀវ សំផន ដែលបានស្លាប់បាត់បង់ជីវិតទៅហើយ ។ សាក្សីបានលើកឡើងបន្ថែមថារូបថតដែលបង្ហាញពីថ្នាក់ដឹកនាំខ្មែរក្រហមជា

ប្រធានរាជរដ្ឋាភិបាលបង្រួបបង្រួម និងរណសិរ្សរំដោះជាតិកម្ពុជាត្រូវបានចាត់ទុកថាជារូបថតក្លែងក្លាយ ។ ពេលនោះ មានភាពមិនច្បាស់លាស់ថា តើថ្នាក់ដឹកនាំខ្មែរក្រហមពិតជាមានអំណាចឬក៏អត់ ពីព្រោះអំណាចពិតប្រាកដ អាចស្ថិតក្នុងដៃវៀតណាមដែលជាអ្នកគ្រប់គ្រងចលនាខ្មែរក្រហម ។

សាក្សីចាំបានថា ខ្លួនធ្លាប់អះអាងនៅក្នុងអត្ថបទព័ត៌មានរបស់ខ្លួនដែលបញ្ជាក់ថា វៀតណាម ពុំមានអំណាចលើខ្មែរក្រហមនោះទេ ហើយអត្ថបទនេះមិនត្រូវបានចេញផ្សាយដោយសារតែភ្នាក់ងារសម្ងាត់ សេ. អ៊ី.អា នៅទីក្រុង Langley សហរដ្ឋអាមេរិកបានប្រាប់អ្នកគ្រប់គ្រងការបោះពុម្ពកាសែតថាការយល់ឃើញរបស់សាក្សីមិនត្រឹមត្រូវទេ ។

សាក្សីនៅចាំបានថា ខ្លួនបានសម្ភាសន៍ជាមួយ ដួន ប្រសិទ្ធ ជាច្រើនដងមកហើយ ប៉ុន្តែពុំមែននៅក្នុងឆ្នាំ១៩៧៨នោះទេ។ សាក្សីក៏លើកឡើងថាខ្លួនបានជួបនឹង ដួន ប្រសិទ្ធ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមរយៈបទសម្ភាសន៍មួយជាមួយ ដួន ប្រសិទ្ធ សាក្សីបានលើកឡើងថា ប្រសិទ្ធ ចាត់ទុក ខៀវ សំផន ដូចជាលេខារបស់ នួន ជា ។

មេធាវី ហ្គីសសេ បានសួរសាក្សី ថាតើគាត់បានឃើញបទសម្ភាសន៍រវាងការិយាល័យសហចៅក្រមស៊ើបអង្កេតជាមួយ ដួន ប្រសិទ្ធ ដែរឬទេនៅពេលដែលខ្លួនធ្វើការនៅក្នុងការិយាល័យនេះ ។ សាក្សីបានឆ្លើយតបថា ខ្លួនបានដឹងអំពីឯកសារនេះ ហើយប្រហែលជាបានជួយណែនាំអ្នកស៊ើបអង្កេតដែលបានធ្វើបទសម្ភាសន៍នេះទៀតផង ។

ឯកសារ E3/96 បទសម្ភាសន៍រវាងការិយាល័យសហចៅក្រមស៊ើបអង្កេតជាមួយ ដួន ប្រសិទ្ធ ត្រូវបានដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រ ។ សហព្រះរាជអាជ្ញា វ៉ើយន័រ បានជំទាស់ថាឯកសារនេះមិនបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ហើយសហព្រះរាជអាជ្ញាពុំបានដឹងអំពីការដាក់បង្ហាញឯកសារនេះទេ ។ មេធាវី ហ្គីសសេ បានសុំទោសចំពោះការខកខានក្នុងការ ជូនដំណឹងដល់សហព្រះរាជអជ្ញា ហើយអង្គជំនុំជម្រះបានអនុញ្ញាតឲ្យបង្ហាញឯកសាររបស់ខ្លួន
ដោយសារឯកសារនេះមានលេខសម្គាល់រួចហើយគឺ E3 ។

ទាក់ទងនឹង ខៀវ សំផន លោក ដួន ប្រសិទ្ធ បាននិយាយប្រាប់អ្នកយកបទសម្ភាសន៍ថាខ្លួនមិនច្បាស់ថាបានស្គាល់ ខៀវ សំផន នៅប្រទេសបារាំងនោះទេ ប៉ុន្តែបានជួប និងស្គាល់ ខៀវ សំផន ពេលដែល ខៀវ សំផន ចាប់ផ្តើមបោះពុម្ពការសែត *L' Observateur* ហើយ លោក ប្រសិទ្ធ បានសរសេរអត្ថបទបោះពុម្ពសម្រាប់ការសែតនេះផងដែរ ។ ខៀវ សំផន ត្រូវបានសាធារណជនចាត់ទុកថាជាមនុស្សស្អាតស្អំម្នាក់ ។

នៅក្នុងបទសម្ភាសន៍នោះបានលើកឡើងថា ខៀវ សំផន ជាអគ្គមេញ្ជាការជាន់ខ្ពស់នៃកងទ័ពកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែនេះគ្រាន់តែជាតំណែងក្លែងក្លាយតែប៉ុណ្ណោះ ព្រោះ ប៉ុល ពត ជាអ្នកដែលមានអំណាចគ្រប់គ្រងកងទ័ពខ្មែរក្រហម ។ លោក ប្រសិទ្ធ បាននិយាយថាពេលធ្វើទស្សនកិច្ចនៅឯបរទេស អៀង សារី ជាអ្នកមានដែលអំណាច និងសម្រេចកិច្ចការនានា ពុំមែន ខៀវ សំផន នោះទេបើទោះបីជា ខៀវ សំផន គឺជាប្រធានគណៈប្រតិភូក៏ដោយ ។

សាក្សីបានលើកឡើងថាខ្លួនបានឃើញបទសម្ភាសន៍នេះ ប៉ុន្តែពុំបានធ្វើការវិភាគនោះទេ ។ សាក្សីក៏បានបន្ថែមថា ការលើកឡើងនៅក្នុងបទសម្ភាសន៍អំពីតួនាទីរបស់ ខៀវ សំផន ជាអគ្គមេបញ្ជាការ ជាន់ខ្ពស់នោះគឺជារឿងត្រឹមត្រូវ ។ សាក្សីពុំមានឯកសារដើម្បីបញ្ជាក់ថា ខៀវ សំផន ជាលេខាផ្ទាល់របស់ នួន ជា នោះទេ ។

ក្នុងសក្ខីកម្មរបស់ខ្លួនកាលពីថ្ងៃទី១១ សាក្សីបានពិភាក្សាពីការព័ត៌មានដែលផ្សព្វផ្សាយតាមវិទ្យុ "សម្លេងរបស់រណសិរ្សរំដោះជាតិកម្ពុជា" ។ ខៀវ សំផន បានធ្វើសេចក្តីរាយការណ៍ដោយផ្ទាល់ និងជាច្រើនសារក្នុងវិទ្យុសម្លេងរបស់រណសិរ្សរំដោះជាតិកម្ពុជា ប៉ុន្តែ ខៀវ សំផន ពុំបានប្រកាសឈ្មោះរបស់ខ្លួន នៅពេលរាយការណ៍ព័ត៌មាននៅក្នុងវិទ្យុនោះទេ ។ សាក្សីបានបញ្ជាក់ថារបាយការណ៍របស់ទីភ្នាក់ងារផ្សព្វផ្សាយព័ត៌មានអន្តរជាតិមានបញ្ជាក់អំពីឈ្មោះអ្នកធ្វើសេចក្តី រាយការណ៍ក្នុងវិទ្យុសម្លេងរបស់រណសិរ្សរំដោះជាតិកម្ពុជា ។ សាក្សីពុំបានចាំឈ្មោះអ្នករាយការណ៍ព័ត៌មានរបស់វិទ្យុសម្លេងរបស់រណសិរ្សរំដោះជាតិកម្ពុជា ដែលប្រកាសឈ្មោះរបស់ខ្លួនមុនពេលរាយការណ៍ព័ត៌មាននោះទេ ។

មេធាវីការពារក្តីបានរំឭកដល់សាក្សីថា កាលពីលើកមុន សាក្សីបាននិយាយថារាល់សេចក្តីសម្រេចពុំមែនសុទ្ធតែបានធ្វើតាមនីតិវិធីជាផ្លូវការនោះទេ ។ បន្ទាប់មក មេធាវីបានអានសេចក្តីដកស្រង់ពីសៀវ

ភៅ ដែលមានចំណងជើងថា«ពិចារណាឡើងវិញពីតួនាទីរបស់មេដឹកនាំ និងកម្មាភិបាលថ្នាក់ក្រោមនៃរបបកម្ពុជាប្រជាធិបតេយ្យ» ដែលសាក្សីបានសរសេរនៅក្នុងជំពូកមួយនៃសៀវភៅរបស់ខ្លួនមានចំណងជើងថា«ប៉ុល ពត និង ខៀវ សំផន» ជូនសាក្សី ហើយក្នុងនោះសាក្សីបញ្ជាក់ថា«ដើម្បីធ្វើឲ្យប្រជាជនថ្មីក្លាយជាផ្នែកមួយរបស់សង្គម ប្រជាជនមូលដ្ឋានត្រូវបានណែនាំឲ្យបើកចិត្តឲ្យទូលំទូលាយ ហើយពុំចាត់ទុកប្រជាជនថ្មីជាឈ្លើយសឹកសង្គ្រាម» ។

គោលនយោបាយផ្លូវការណ៍ដែលមានលើកឡើងក្នុងការដកស្រង់នេះបញ្ជាក់ថា «ប្រជាជនមូលដ្ឋានត្រូវលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនថ្មីដើម្បីធ្វើយ៉ាងណាឲ្យប្រជាជនថ្មី គិតថាបដិវត្តន៍នេះជាបដិវត្តន៍របស់គេផងដែរ» ។ សាក្សីបញ្ជាក់ថាគាត់បានបកប្រែការលើកឡើងខាងលើនេះពីភាសារខ្មែរ ហើយបានសរសេរចូលនៅក្នុងសៀវភៅរបស់ខ្លួនដើម្បីសង្ខេបពីគោលនយោបាយនេះ ។

មេធាវីការពារក្តី ហ្គីសសេ បានលើកឡើង និងបង្ហាញជូនសាក្សីពីកំណត់សម្គាល់ជើងទំព័រទី៣១-៤១ និងឯកសារក្នុងកំណត់សម្គាល់ជើងទំព័រទាំងនេះ ដើម្បីឲ្យសាក្សីបញ្ជាក់ថា ឯកសារទាំងអស់នេះមាននៅក្នុងសំណុំរឿងដែលមេធាវីការពារក្តីបានលើកយកមកប្រើប្រាស់ ។ មេធាវីការពារក្តីបង្ហាញឯកសារ E3/216 ជូនសាក្សី ហើយសាក្សីបានបញ្ជាក់ថា ខ្លួនទទួលបានឯកសារនេះពីមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏បានមកពីលោក ដេវីដ ឆេនដល័រ ។ កំណត់សម្គាល់ជើងទំព័រទី៣២ ជាឯកសារ «កំណត់ហេតុស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ» ហើយសាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ឯកសារនេះជាកំណត់ហេតុផ្ទាល់ខ្លួនរបស់កម្មាភិបាលខ្មែរក្រហម ។ កំណត់សម្គាល់ជើងទំព័រទី៣៩ជាឯកសាររបស់បក្ស ដែលយកមកពីមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

សាក្សីបានពន្យល់ថា សរុបមកគោលនយោបាយដែលលើកយកមកពិភាក្សានេះ ត្រូវបានដកស្រង់ចេញ ពីឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា និងបទសម្ភាសន៍ដែលសាក្សីបានធ្វើជាមួយនឹងជនភៀសខ្លួន ។

បន្ទាប់ពីម្រាកពេលព្រឹក មេធាវី ហ្គីសសេ បានពន្យល់ថា ខ្លួននឹងលើកឡើងនូវឯកសារដែលបញ្ជាក់ពីភាពខុសគ្នារវាងការដឹកនាំ និងការអនុវត្តន៍ជាក់ស្តែង ។

ឯកសារទីមួយ D224.77 ជាបទសម្ភាសន៍នៅខេត្តពោធិ៍សាត់ ថ្ងៃទី១៤ តុលា ឆ្នាំ២០០៥ ។ នៅក្នុងបទសម្ភាសន៍នេះបានបង្ហាញថា «នៅឆ្នាំ១៩៧៧ យើងធ្វើស្រូវពីរដងក្នុងមួយឆ្នាំ ដោះស្រាយបញ្ហាផ្គត់ផ្គង់ទឹកដាក់ស្រែ និងទទួលបានផលពីរតោនក្នុងមួយហិចតា ។ ប្រជាជនក្នុងម្នាក់ទទួលបានអង្ករពីរកំប៉ុង ប៉ុន្តែជាក់ស្តែងប្រជាជនម្នាក់ទទួលបានអង្ករតែមួយកំប៉ុងប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ផលស្រូវមានគ្រប់គ្រាន់សម្រាប់ប្រជាជនហូបចុក ប៉ុន្តែភាគច្រើនត្រូវបាននាំចេញទៅបរទេស» ។

ឯកសារនេះបានលើកឡើងថា ថ្នាក់ស្រុកត្រូវតែធ្វើតាមផែនការនេះឲ្យបាន ។ ប្រសិនបើប្រជាជនទទួលរបបអាហារច្រើនលើសលប់ស្រុកនឹងទទួលបានការព្រមាន ប៉ុន្តែបើការបែងចែករបបអាហារឲ្យប្រជាជនមិនគ្រប់គ្រាន់ត្រូវបានអនុញ្ញាត ។

សាក្សីបានបញ្ជាក់ថា ខ្លួនបានសរសេរព័ត៌មានក្នុងសៀវភៅកំណត់ហេតុ ហើយសាក្សីផ្ទាល់ជាអ្នកប្រែពីភាសាខ្មែរដោយខ្លួនឯង ។ ពេលរៀបចំកំណត់ហេតុរបស់ខ្លួន សាក្សីបានបញ្ជាក់ថាកំហត់ហេតុទាំងនោះមានប្រើ Articles ដូចជា a an និង the ។ សាក្សីបានបញ្ជាក់ទៀតថាខ្លួនបានសង្ខេបបទសម្ភាសន៍ទាំងនោះ ដោយមិនមែនចម្លងចេញបទសម្ភាសន៍នោះទាំងស្រុងទេ ហេតុដូច្នេះហើយបានជាមិនមានសំនួររបស់សាក្សីនៅក្នុងបទសង្ខេបទាំងនោះទេ ។

ក្នុងអំឡុងពេលសួរដេញដោល សាក្សីបានរៀបរាប់ថា បើទោះបីជាខ្លួនបានលើកឡើងនូវព័ត៌មានជាច្រើនដើម្បីគាំទ្រគំនិតរបស់ខ្លួន សាក្សីបានដឹងពីការគិត និងអះអាងផ្សេងពីខ្លួនផងដែរ ។

បន្ទាប់មក មេធាវី ហ្គីសសេ បានដកស្រង់នូវបទសម្ភាសន៍មួយដែលរៀបរាប់ថា «នៅខែមេសា ឆ្នាំ១៩៧៥ មានសេចក្តីណែនាំដែលបញ្ជាក់ឲ្យប្រជាជន១៧ និងប្រជាជន១៨ ហូបរួមគ្នា ហើយយើងមិនគួរចាត់ឲ្យអ្នក១៧ ធ្វើការធ្ងន់ជាងយើងនោះទេ» ។

សាក្សីបានបញ្ជាក់ថា ប្រជាជន១៨ គឺសំដៅទៅលើប្រជាជនដែលរស់នៅក្រោមរបបកុម្មុយនីស្តនៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ហើយប្រជាជន១៧ សំដៅទៅលើប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ សាក្សីបាននិយាយថា កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមបានលើកឡើងអំពីការបែងចែកនេះ ។

ឯកសារបទសម្ភាសន៍មួយទៀតមានលេខ D224.31 ត្រូវបានដាក់បង្ហាញជូនសាក្សី ។ អ្នកផ្តល់បទសម្ភាសន៍ដែលពុំមានទាក់ទងនឹងតុលាការបាននិយាយថា ប្តីរបស់បងប្អូនស្រីខ្លួនត្រូវបានចាប់ខ្លួនដោយសារតែគាត់ជាអតីតមន្ត្រីស៊ីវិលរបស់របប លន់ នល់ ។ គាត់ត្រូវបានចោទប្រកាន់ថាជាអ្នកស៊ុំលុយពីរបបមុន ។

បន្ទាប់ពីមានបញ្ហាក្នុងការបកប្រែភាសា មេធាវីការពារក្តី បានចោទសួរសាក្សីថា តើសាក្សីធ្លាប់បានដឹងព័ត៌មានទាក់ទងនឹងមនុស្សមួយចំនួនដែលត្រូវបានចាប់ខ្លួនដោយសារតែមានបញ្ហាជាមួយនឹងអាជ្ញាធរមូលដ្ឋានដែរឬទេ ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានឃើញការលើកឡើងបែបនេះជាញឹកញាប់នៅក្នុងឯកសារដែលគាត់បានពិនិត្យ ។

មេធាវី ហ្គីសសេ បានអានសេចក្តីដកស្រង់ចេញពីឯកសារ E/1714 «បទសម្ភាសន៍ដ៏ល្បី» ដែលសាក្សីបានធ្វើជាមួយនឹងជនភៀសខ្លួននៅតាមព្រំដែនថៃក្នុងខែមិនា ឆ្នាំ១៩៨០ ។ អតីតកម្មាភិបាលខ្មែរក្រហមដែលធ្លាប់ធ្វើការនៅក្នុងក្រសួងការបរទេសបានលើកឡើងថា មេដឹកនាំថ្នាក់លើមិនបានធ្វើការស៊ើបអង្កេតពីសភាពការណ៍ជាក់ស្តែងនៅថ្នាក់មូលដ្ឋាននោះទេ ដោយសារតែក្រុមនេះអង្គុយតែនៅក្នុងការិយាល័យ និងអានរបាយការណ៍ដែលផ្ញើរមកតែប៉ុណ្ណោះ ។

មេធាវីការពារក្តីបានសួរថា តើសាក្សីបានដឹងថាកម្មាភិបាលថ្នាក់លើមិនបានទទួលព័ត៌មានទាំងអស់ពីថ្នាក់ក្រោមពិតមែនដែរឬទេ? សាក្សីក៏បានឆ្លើយបញ្ជាក់ថា មនុស្សដែលគាត់បានសម្ភាសន៍ក៏បានលើកឡើងដូច្នេះដែរ ។ សាក្សីជឿជាក់ថា ការលើកឡើងក្នុងឯកសារបន្ទាប់ដែលបានអានជូនអង្គជំនុំជម្រះនេះពុំមែនជារឿងដែលកើតឡើងញឹកញាប់នោះទេ ។ ឯកសារ ERN001730 បានលើកឡើងថា «ជាទូទៅតំបន់នីមួយៗមានរៀបចំសមាជ ហើយចេញសេចក្តីសម្រេចអំពីបរិមាណស្រូវដែលត្រូវផលិត» ។ សមាជផ្សេងទៀត ត្រូវចេញសេចក្តីសម្រេចលើបរិមាណស្រូវដែលត្រូវបញ្ជូនទៅថ្នាក់លើ» ។ សាក្សីបានឆ្លើយតបថា ការលើកឡើងដូចខាងនេះ គឺកម្រនឹងកើតមានណាស់ ដោយសារតែថ្នាក់លើពុំដែលកំណត់អំពីបរិមាណនោះទេ ។ ការលើកឡើងខាងលើនេះគឺជាករណីដ៏ពិសេសបំផុត ។

ឯកសារ ERN00170714 អះអាងថាលេខាស្រុកនិងតំបន់ជាអ្នកទទួលខុសត្រូវការសម្លាប់ប្រជាជនជាជាង ប៉ុល ពត ។ សាក្សីបញ្ជាក់ថាខ្លួនបានដឹងពីព័ត៌មានបែបនេះជាញឹកញាប់ ។

ដូចគ្នានេះដែរ ឯកសារ ERN0017723 និយាយអំពីការផ្តល់អំណាចទៅមេដឹកនាំថ្នាក់មូលដ្ឋាន ។ ព័ត៌មាននេះបានមកមនុស្សម្នាក់ដែលរស់នៅក្នុងភូមិភាគនិរតី ហើយប្រហែលជាសមាជិកបក្សទៀតផង ។ អ្នករស់រានមានជីវិតរូបនេះលើកឡើងថា «ស្ថានភាពនៅប៉ែកពាយ័ព្យមានលក្ខណៈចំឡែកមែនទែន» ។ «នៅមុនឆ្នាំ១៩៧៦ សហករណ៍មិនទាន់កើតចេញជារូបរៀងនោះទេ ។ ប្រជាជនមូលដ្ឋានភ័យខ្លាច នៅពេលឃើញកម្មាភិបាលខ្មែរក្រហមមក ។ ខ្ញុំបានពន្យល់ប្រជាជនមូលដ្ឋានថាមិនមានទំនាក់ទំនងសក្តិភូមិក្នុងបដិវត្តន៍នេះឡើយ ។ ពាក្យសក្តិភូមិត្រូវបានលើកយកមកនិយាយ ដោយសារតែមានកម្មាភិបាលមួយចំនួនធ្វើខ្លួនដូចជាស្តេចក្រាញ់បែបសក្តិភូមិ» ។

សាក្សីបានដឹងថាប្រជាជនមូលដ្ឋានខ្លាចប្រជាជនកម្មាភិបាលខ្មែរក្រហម ប៉ុន្តែមិនដែលបានដឹងពីការប្រៀបធៀបកម្មាភិបាលខ្មែរក្រហមទៅនឹងស្តេចក្រាញ់នោះទេ ។

មេធាវី ហ្គីសសេ បង្ហាញឯកសារបន្ទាប់ E3/198 ។ ឯកសារនេះនិយាយពី«សេចក្តីសង្ខេប»របស់បទសម្ភាសន៍ជាមួយ ខៀវ សំផន ដោយលើកឡើងថា«ខៀវ សំផន នៅក្នុងភូមិភាគមួយៗ លេខាភូមិភាគជាស្តេចត្រាញ់ ហើយធ្វើការគ្រប់គ្រងភូមិភាគនីមួយៗតាមតែចិត្តរបស់ខ្លួន» ។ ខៀវ សំផនលើកឡើងថាថ្នាក់លើមិនបានដឹងពីការចាប់ខ្លួនជាច្រើន ។ សាក្សីជម្រាបអង្គជំនុំជម្រះថាខ្លួនមិនបានធ្វើ និងបកប្រែបទសម្ភាសន៍នេះទេ ។

ពេលដែលស្នើរឲ្យធ្វើការបកស្រាយលើបញ្ហានេះ សាក្សីបញ្ជាក់ប្រាប់មេធាវី ហ្គីសសេ ថាខ្លួន សំជាអ្នកសម្ភាសន៍ ខៀវសំផន ។ សាក្សីបន្ថែមថាការបកប្រែនេះប្រហែលជាការបកប្រែរបស់តុលាការ ។

មេធាវីការពារដាក់បង្ហាញឯកសារ 00089756 ជូនសាក្សី ។ ឯកសារនេះជាបទសម្ភាសន៍ជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ដែលមិនបញ្ចេញឈ្មោះនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៥ ។ សាក្សីបានធ្វើបទសម្ភាសន៍ជាមួយនឹងកម្មាភិបាលរូបនេះ ប៉ុន្តែសាក្សីបានកែតម្រូវពីការបរិច្ឆេទ ដោយសារតែបទសម្ភាសន៍នេះធ្វើឡើងក្នុងឆ្នាំ១៩៨០ នៅជំរុំភៀសខ្លួនអង្គការសហប្រជាជាតិតាមព្រំដែនថៃ ។ បទសម្ភាសន៍លើកឡើងថា «នៅពិធីគំរប់ខួប ១៧ មេសា ប៉ុល ពត តែងតែធ្វើអ្នកថ្លែងការណ៍ ។ ខៀវ សំផន មិនបានលើវេទិការកិត្តយស ។ មានពេលមួយនៅក្នុងឆ្នាំ១៩៧៥ មានមនុស្សជាច្រើននៅលើវេទិការកិត្តយស ប៉ុន្តែក្រោយមកទៀតមានតែ តាម៉ុក ប្រ នួន ជា ប៉ុណ្ណោះដែលនៅលើឆាក» ។

## សហព្រះរាជអជ្ញាដាក់សំណើសុំទាក់ទងនឹងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សី

បន្ទាប់ពីពេលសម្រាកអាហារថ្ងៃត្រង់ សហព្រះរាជអាជ្ញាលើកឡើងពីបញ្ហាច្បាប់មកពិភាក្សា ។ សហព្រះរាជអាជ្ញាលើកឡើងថាដោយហេតុតែមេធាវីការពារក្តីទាំងពីរក្រុមយកកំណត់ហេតុចម្លើយសាក្សីដែលមិនបានឡើងផ្តល់សក្ខីកម្ម  មេធាវីទាំងពីរក្រុមលែងមានគោលជំហរប្រឆាំងនឹងការអនុវត្តន៍របស់សហព្រះរាជអជ្ញាក្នុងការប្រើប្រាស់សក្ខីកម្មរបស់សាក្សីជាជាងសក្ខីកម្មផ្ទាល់មាត់ ។

ជាការឆ្លើយតប មេធាវី  ហ្គីសសេ លើកឡើងថាភាគីគួរចាំបាច់ចាំថាមេធាវីការពារមិនមានចេតនាផ្លាស់ប្តូរគោលជំហររបស់ខ្លួនឡើយ ។  លើសពីនេះទៅទៀត  ការសួរដោញដោលសាក្សីមានភាពខុសគ្នាពីការលើកឡើងរបស់ព្រះរាជអាជ្ញាពីព្រោះមេធាវីការពារក្តីប្រើកំណត់ហេតុចម្លើយសាក្សីដើម្បីបានការឆ្លើយតបពីសាក្សី  ហើយការធ្វើបែបនេះមិនមែនជាការដាក់បង្ហាញភស្តុតាងនោះទេ ។

មេធាវី  ហ្គីសសេ លើកឡើងថាវិធីសាស្រ្តនៃការសួរដេញដោលបែបនេះមានសារសំខាន់ សម្រាប់ករណីដែលមេធាវីការពារក្តីមិនអាចសួរសាក្សីជំនាញបាន ។  ហេតុដូច្នេះហើយ  អង្គជំនុំជម្រះមិនគួរចាត់ទុកឯកសារដែលបង្ហាញជូនជាចម្លើយនោះទេ ប៉ុន្តែគួរចាត់ទុកការឆ្លើយតបរបស់សាក្សីជាចម្លើយ ។

អង្គជំនុំជម្រះ ចាត់ឲ្យមេធាវីការពារក្តី នួន ជា សុន អរុណ ឆ្លើយតបនឹងសំណើររបស់សហព្រះរាជអាជ្ញា ។ មេធាវី  សុន  អរុណ  មិនបានធ្វើតាមការចាត់តាំងរបស់អង្គជំនុំជម្រះ  ប៉ុន្តែបែរជាលើកឡើងវិញថាកូនក្តីរបស់ខ្លួនថ្លែងទៅកាន់អង្គជំនុំជម្រះ ។  ក្រោមសម្ពាធរបស់លោកប្រធានអង្គជំនុំជម្រះសាលាដំបូង  សហសេវិក  របស់មេធាវី  សុន  អរុណ  វ៉ិចទ័រ  កុបប៉េ  ឆ្លើយតបនឹងអង្គជំនុំជម្រះថាក្រុមរបស់ខ្លួននឹងធ្វើការឆ្លើយតបទៅកាន់សហព្រះរាជអាជ្ញាជាលាយលក្ខអក្សរ ។

## នួន  ជា  ថ្លែងទៅកាន់អង្គជំនុំជម្រះ

នួន  ជា  បង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះតាមរយៈប្រព័ន្ធវីដេអូ ។  ខុសពីការស្លៀកពាក់កន្លងមក នួន ជា អង្គុយលើកៅអី ហើយមិនពាក់វ៉ែនតាការពារពន្លឺថ្ងៃ ។ គាត់ថ្លែងទៅកាន់អង្គជំនុំជម្រះថា ៖

> សូមគោរពលោក លោកស្រីចៅក្រម ។ ខ្ញុំសូមលើកឡើងនូវការជូនដំណឹងខ្លីមួយទៅលោកលោកស្រីចៅក្រម ។ ដូចដែលខ្ញុំតែងតែបានលើកឡើងមកហើយថា តុលាការនេះមិនបានគោរពទៅលើគោលការណ៍នៃការកាត់សេចក្តីដ៏ត្រឹមត្រូវ និងយុត្តិធម៌នោះទេ ។ ខ្ញុំបានសង្កេតឃើញការប្រព្រឹត្តមកលើជនជាប់ចោទ ក៏ដូចជាក្រុមមេធាវីការពាររបស់ខ្ញុំវិវត្តន៍ពីអាក្រក់ទៅកាន់តែអាក្រក់ថែមទៀត ។ ខ្ញុំក៏អស់ជំនឿនឹងតុលាការនេះ ដូចលោក ខៀវ សំផន ដែរ ។
>
> ការប្រព្រឹត្តរបស់តុលាការមកលើខាងយើងខ្ញុំគឺនៅភពម្ខាង ហើយលម្អៀងទៅខាងសហព្រះរាជអាជ្ញា ។ ជាក់ស្តែងដូចជានៅពេលថ្មីនេះ មេធាវីរបស់ខ្ញុំត្រូវបានកាត់ផ្តាច់មិនឲ្យសួរសំណួរជាសារធាតុ ដើម្បីដោះស្រាយបន្ទុកមកលើរូបខ្ញុំនោះទេ ។ នេះជាភាពអយុត្តិធម៌មួយ ដែលរារាំងមិនឲ្យមេធាវីរបស់ខ្ញុំបំពេញតួនាទីការពារខ្ញុំដោយពេញលេញ ។ នេះជារឿងក្តីនៃអាយុជីវិតរបស់ខ្ញុំ មិនមែនជាធ្វើលំៗឲ្យតែឆាប់រហ័សដើម្បីដាក់ទោសខ្ញុំនោះទេ ។
>
> ដោយភាពអស់ជំនឿ និងប្រព្រឹត្តដោយលម្អៀងបែបនេះ ខ្ញុំសូមជូនដំណឹងថា ខ្ញុំមិនឆ្លើយតបទៅនឹងសំណួររបស់ព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋបវេណីនៅក្នុងតុលាការដែលមិនយុត្តិធម៌នេះទេ ។

បន្ទាប់ពី នួន ជា បញ្ចប់សេចក្តីថ្លែងការណ៍របស់ខ្លួន សហព្រះរាជអាជ្ញា ថារីក អាប់ឌុលហាក់ លើកឡើងនូវបញ្ហាដូចគ្នានេះ ទាក់ទងនឹងការបដិសេធមិនឆ្លើយនឹងសំណួររបស់ ខៀវ សំផន ប៉ុន្តែពេលនេះ នួន ជា បដិសេធមិនឆ្លើយតបនឹងសំណួរដូចគ្នាដែរ ។

សហព្រះរាជអជ្ញាបញ្ជាក់ថាចុងចោទមានសិទ្ធិនៅស្ងៀមមិនបញ្ចេញមតិ ហើយសេចក្តីសន្និដ្ឋានផ្ទុយគួរតែត្រូវបានលើកមកគាំទ្រការបដិសេធមិនផ្តល់សក្ខីកម្ម ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាដាក់សំណើរផ្ទាល់មាត់ឆ្លើយតបនឹង ខៀវ សំផន និង នួន ជា ។ លើសពីនេះទៀត សហព្រះរាជាអាជ្ញជឿជាក់ថា អង្គជំនុំជម្រះអាចប្រើសេចក្តីសន្និដ្ឋានផ្ទុយដើម្បីដោះស្រាយនឹងបញ្ហាមិនឆ្លើយតបរបស់ចុងចោទ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រការលើកឡើងរបស់សហព្រះរាជអាជ្ញា ដោយបញ្ជាក់ថា មេធាវីដើមបណ្តឹងភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលចុងចោទព្យាយាមធ្វើខ្លួនជាជនរងគ្រោះ ។

ឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាដែលបានស្នើឲ្យអង្គជំនុំជម្រះ លើកយកសេចក្តីសន្និដ្ឋានផ្ទុយមកអនុវត្ត មេធាវី ហ្គីសសេ ស្នើឲ្យអង្គជំនុំជម្រះប្រានចោលសំណើររបស់សហព្រះរាជអាជ្ញា ពីព្រោះថាការលើកឡើងបែបនេះគួរតែធ្វើឡើងក្នុងសេចក្តីថ្លែងបិទទៅវិញទេ ។

សហព្រះរាជអាជ្ញា អាប់ឌុលហាក់ ឆ្លើយតបវិញថាការស្នើសុំបែបនេះធ្វើឲ្យចុងចោទទទួលបានប្រ-យោជន៍តែម្ខាង ពីព្រោះថាចុងចោទនឹងបន្តប្រើសិទ្ធិនៅស្ងៀមមិនបញ្ចេញមតិរបស់ខ្លួន ហើយប៉ះពាល់ដល់ដំណើរកាត់ទោសនេះ ។

ចៅក្រម ស៊ីលវៀ ខាតហ្វ៊ាយត៍ ឆ្លើយតបនឹងសំណើរនេះ ។ ចៅក្រម ខាតហ្វ៊ាយត៍ សម្រេចថា អង្គជំនុំជម្រះនឹងដោះស្រាយបញ្ហាដាក់ភស្តុតាងតាមសក្ខីកម្មផ្ទាល់មាត់ជាមួយនឹងសាលក្រម ។

## មេធាវី ខៀវ សំផន បន្តសួរដេញដោលសាក្សី

មេធាវី ហ្គីសសេ បន្តដេញដោលសាក្សីដោយលើកយកឯកសារ 19.71 មកពិភាក្សា ។ ឯកសារនេះលើកឡើងថា «អ្នកបេះដូង» នៅក្រុងភ្នំពេញមិនបានដឹងពីភាពអត់ឃ្លាននៅជនបទនោះទេ ។ «នៅឆ្នាំ ១៩៧៦ ពេលដែលយើងហូបបបរ យើងគិតថានៅជនបទប្រហែលជាខ្វះស្បៀង ។ ប៉ុន្តែ យើងគិតថាស្បៀងនឹងកើនឡើងក្នុងឆ្នាំ១៩៧៧ ។ វិទ្យុ និងទស្សនាវដ្តី បានលើកឡើងបែបនេះ» ។

សាក្សីនិយាយថាខ្លួនបានដឹងពីអ្នកបេះដូង ដែលមិនមែនជាសមាជិកបក្សក្នុងក្រុងភ្នំពេញលើកឡើងថាខ្លួនបានជួបនឹងហេតុការណ៍បែបនេះដែរ ។ អ្នកបេះដូងផ្សេងទៀតប្រាប់សាក្សីថា ពួកគាត់បានដឹងពីអ្វីដែលកើតឡើងនៅជនបទ ។ បន្ទាប់ពីបានស្តាប់ការដកស្រង់មួយទៀត សាក្សីជម្រាបទៅអង្គជំនុំជម្រះថា ខ្លួនបានដឹងពីព័ត៌មានដែលប្រជាជនមូលដ្ឋានព្យាយាមលាក់បាំងការពិតនៅពេលដែលថ្នាក់លើចុះទៅសង្កេតមើលសភាពការណ៍ជាក់ស្តែងនៅថ្នាក់មូលដ្ឋានមួយចំនួន ។

បន្ទាប់មកទៀត មេធាវី ហ្គីសសេ ពិភាក្សាពីកិច្ចការរបស់សាក្សីជាមួយនឹងតុលាការ ហើយលើកឡើងថាសាក្សីទទួលបានភារកិច្ចដ៏សំខាន់មួយនៅក្នុងតុលាការ ដោយសារតែសាក្សីចេះភាសារខ្មែរ ។ ពេលដែលសាក្សីសម្ភាសន៍សាក្សីរបស់តុលាការ គាត់សម្ភាសន៍សាក្សីជាភាសារខ្មែរ ជាមួយនឹងមន្ត្រីស៊ើបអង្កេតជនជាតិខ្មែរ ។ សាក្សីអាចពិនិត្យមើលឯកសារទាំងអស់លើកលែងតែឯកសារ«សម្ងាត់បំផុត» ។ មេធាវីការពារក្តី អានឯកសារ E/31/69 ដែលនិយាយអំពីកិច្ចប្រជុំមជ្ឈិមបក្សនៅខែកុម្ភៈ ឆ្នាំ១៩៧៦ ជូនអង្គជំនុំជម្រះ ។ របៀបវារៈនៅក្នុងកិច្ចប្រជុំនោះនិយាយអំពីបញ្ហាសន្តិសុខជាតិ ដោយបញ្ជាក់ថា «សមមិត្តខៀវ បានរាយការណ៍កាលពីដើមខែកុម្ភៈថា វៀតណាមបានធ្វើសកម្មភាពតាមព្រំដែន ហើយបានចូលមកក្នុងទឹកដីយើងប្រហែលជាពីរទៅបីគីឡូម៉ែត ។ ពេលដែលយើងដេញវា វាដកថយ ។ ពួកវានិយាយថាមេបញ្ជាការមជ្ឈិមវាជាអ្នកបញ្ជាមក» ។

សាក្សីបានដឹងពីការវាយប្រយុទ្ធនោះតាមរយៈទូរលេខ និងរបាយការណ៍ដែលចេញពីភូមិភាគបូព៌ា និងបទសម្ភាសន៍ដែលខ្លួនបានធ្វើ ។ ការវាយប្រយុទ្ធជាមួយនឹងវៀតណាមកើតឡើងតាំងពីមុនខែមេសា ឆ្នាំ១៩៧៥ និងនៅចន្លោះឆ្នាំ១៩៧៦ និង១៩៧៧ ។

បន្ទាប់ពីម៉ោងសម្រាកពេលរសៀល សហព្រះរាជអជ្ញាបន្តដេញដោលសាក្សីពីបញ្ហាការពារជាតិ ដោយសួរថា តើសាក្សីបានឃើញឯកសារដែលបញ្ជាក់ពីតួនាទីរបស់មន្ទីរ៨៧០ដែរឬទេ ។ សាក្សីឆ្លើយតបថាខ្លួនបានឃើញ ហើយបកស្រាយថាមិនការអះអាងច្បាស់ថាតើមន្ទីរ៨៧០ជាមន្ទីរតែមួយ ឬមួយមានមន្ទីរចំណុះជាច្រើន ។

មេធាវី ហ្គីសសេ បន្តដេញដោលសាក្សីពីប្រធានមន្ទីរ៨៧០ ។ សាក្សីបានពិនិត្យឯកសារដែលនិយាយពីមន្ទីរ៨៧០និងគណៈ៨៧០ ប៉ុន្តែសាក្សីមិនអាចនឹងឃើញពីឯកសារដែលលើកឡើងពីពាក្យពេញរបស់គណៈ៨៧០ ។ សាក្សីបានឃើញឯកសារជាច្រើនដែលប្រើពាក្យ «គណៈ៨៧០» ។ សាក្សីបានដឹងពីពាក្យនេះមុនពេលតុលាការនេះកើតឡើង និងអំឡុងពេលដែលខ្លួនបំពេញការងារនៅ អ.វ.ត.ក ។

សាក្សីបានឃើញពាក្យ «បង៨៧០» នៅក្នុងឯកសារផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជានៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងពេលដែលខ្លួនធ្វើការនៅ អ.វ.ត.ក ។ សាក្សីបញ្ជាក់ថាខ្លួនបានឃើញរបៀបវារៈដែលតុលាការបង្ហាញជូនខ្លួននៅពេលនេះ ។ នៅក្នុងរបៀបវារៈនោះ ខៀន ជា«អ្នកកាន់កាប់ការិយា

ល័យនយោបាយរបស់មន្ទីរ៨៧០» ។ យោងតាមឯកសារខ្មែរ សាក្សីអះអាងថា ខៀន ជាប្រធានមន្ទីរនេះ ឬក៏មន្ទីរនេះជារបស់ ខៀន ។ សាក្សីបានបដិសេធមិនធ្វើការវិភាគបន្តពីព្រោះការវិភាគបែបនេះជាសមត្ថកិច្ចរបស់អ្នកជំនាញ ។

ការសួរដេញដោលបន្តផ្តោតទៅលើបទបង្ហាញឯកសារយ៉ាងវែងដល់សាក្សី និងការធ្វើតេស្តលើសាក្សីពីចំណេះដឹងភាសាខ្មែររបស់ខ្លួន ។ ឯកសារទាំងនោះ មានដូចជាឯកសារE3/235 ដែលនិយាយពីបទសង្ខេបនៃកិច្ចប្រជុំរបស់មជ្ឈិមបក្សនៅឆ្នាំ១៩៧៦ ។ ឯកសារនេះលើកឡើងថា គណៈបង្កើតឡើងដោយ «៨៧០» ។ ឯកសារ E3/220 ជាឯកសារនិយាយពីកិច្ចប្រជុំមជ្ឈិមបក្ស ដែលបញ្ជាក់ថា ខៀន ត្រូវបានបញ្ជូនឲ្យទៅគ្រប់គ្រងគណៈពានិជ្ជរយៈពេលបីរខែ ។ មេធាវី ហ្គីសសេ ចាប់អារម្មណ៍ពីពាក្យ «មន្ទីរ»ក្នុងចំណោមពាក្យទាំងឡាយដែលមាននៅក្នុងឯកសារទាំងនេះ ។ សាក្សីបញ្ជាក់ថា «មន្ទីរ» មានន័យថា Office ជាភាសាអង់គ្លេស ។ សាក្សីបន្ថែមថាពាក្យនេះអាចជាឯកវចនៈ និងពហុវចនៈ ។

មេធាវី ហ្គីសសេ បន្តដេញដោលសាក្សីពីបញ្ហាបកប្រែ ដោយបង្ហាញសាក្សីនូវឯកសារ E3/98 ដែលជាទូរលេខបកប្រែទៅជាភាសារអង់គ្លេស និងភាសារបារាំង ។ បន្ទាប់ពីផ្ទៀងផ្ទាត់ ឯកសារនេះទាំងបីភាសារ សាក្សីបញ្ជាក់ថាឯកសារបកប្រែជាភាសារអង់គ្លេសមិនមានច្បាស់ សាល់និងត្រឹមត្រូវជាភាសារបារាំង ។

មេធាវីការពារក្តីអានសាទូរលេខ E3/902 ជូនសាក្សី ហើយទូរលេខចាប់ផ្តើមដោយ «ជូនចំពោះ៨៧០ ជាទីគោរព» ។ សាក្សីនិយាយជាភាសារខ្មែរថា «ដោយក្តីគោរព ជូនចំពោះគណៈ៨៧០» ។ សាក្សីបន្ថែមថា ពាក្យនេះមិនបានបញ្ជាក់ច្បាស់លាស់ ថាតើជាគណៈទាំងមូល ឬជាបុគ្គល ។

សវនាការបានបញ្ចប់ ហើយនឹងបន្តនៅថ្ងៃព្រហស្បតិ៍ ទី១៨ ខែកក្កដា ឆ្នាំ២០១៣ ដោយមេធាវីក្តីខៀវ សំផន ទទួលបានពេលវេលា មួយម៉ោងកន្លះ បន្ថែមសម្រាប់សួរដេញដោលសាក្សី ។

**– ៧ប់ –**